# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាចិនឆ្នាំសិក្សានៅទេវវិទ្យាល័យ
# ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨

*តើព្រះជាម្ចាស់របស់ព្រះយេស៊ូគង់នៅឯណា?*

| |
|---|
| អត្ថបទទី១៖ ២ពង្ស ២,១.៦-១៤<br>ដំណឹងល្អ៖ មក ៦,១-៦.១៦-១៨ |

បងប្អូនជាទីស្រឡាញ់!

នេះជាពេលវេលាមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់ ថ្ងៃនេះយើងបានស្តាប់សំណួររបស់លោកអេលីសេ ថា "**តើព្រះអម្ចាស់របស់លោកអេលី គង់នៅឯណា?**" ជាសំណួរដែលយើងត្រូវការទុកសម្រាប់ជីវិតរបស់យើង។ ជាសំណួរដែលណែនាំឲ្យយើងមានកម្លាំងខ្លាំង **តើព្រះអម្ចាស់ជាព្រះរបស់ព្រះយេស៊ូគ្រីស្តគង់នៅឯណា?** ជីវិតរបស់យើងគឺស្វែងរកព្រះជាម្ចាស់ ពេលយើងសួរចំណួរនេះអំពីជំនឿរបស់យើងមានចម្លើយដូចលោកអេលីសេ "**ពេលដែលលោកវាយទឹកនោះ ទឹកក៏ញែកចេញពីគ្នាឲ្យលោកដើរឆ្លងកាត់បាន**" ។ ព្រះជាម្ចាស់ បានណែនាំឲ្យគាត់ឃើញអំពីវត្តមានរបស់ព្រះអង្គនៅក្នុងជីវិតរបស់គាត់ និងវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោក។

អត្ថបទគម្ពីរថ្ងៃនេះ "**ព្រះបិតារបស់អ្នក ទតឃើញអំពើដែលអ្នកធ្វើនៅក្នុងទីស្ងាត់កំបាំង ទ្រង់នឹងប្រទានរង្វាន់មកឲ្យអ្នកវិញ**"។ ព្រះបិតា មើលឃើញអ្វីៗទាំងអស់ដែលយើងធ្វើនៅក្នុងទីសម្ងាត់នៃដួងចិត្តរបស់យើង ព្រះបន្ទូលនេះឲ្យយើងទុកដើម្បីដឹកនាំជីវិតរបស់យើងផ្ទាល់ ដឹកនាំចរិតរបស់យើង ឥរិយាបថរបស់យើង។

**ទីមួយ** យើងមិនអាចកុហក់ព្រះជាម្ចាស់ អ្វីដែលយើងធ្វើល្អ ឬមិនល្អព្រះជាម្ចាស់ដឹងទាំងអស់ "**នៅពេលយើងចូលនៅក្នុងទីកាត់ក្តីរបស់ព្រះជាម្ចាស់ នៅពេលនោះយើងនៅខ្លួនទទេ**" យើងមិនអាចលាក់បានទេ។ ឲ្យយើងមានចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់ ព្រះជាម្ចាស់បានកាត់ក្តីឲ្យយើងដើម្បីសង្គ្រោះយើងឲ្យយើងមានជីវិត ជាព្រះដែលពោរពេញដោយមេត្តាករុណា។ ជីវិតរបស់យើង ឲ្យយើងមានចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់ ទោះបីយើងធ្វើខុសក្តី យើងធ្វើខុសក្តីឲ្យយើងទទួលស្គាល់អំពើដែលយើងប្រព្រឹត្តដើម្បីទៅមុខនៅក្នុងភាពដ៏វិសុទ្ធ។ ភាពដ៏វិសុទ្ធ មិនមានន័យថាយើងអស់ស្នាមប្រឡាក់ មិនមិនប្រព្រឹត្តអំពើបាប មានតែព្រះនាងម៉ារីដែលណែនាំឲ្យយើងដឹងថា ភាពដ៏វិសុទ្ធមនុស្សយើងអាចធ្វើបាន។ យើងទីពឹងលើព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។

**ទីពីរ** កុំឲ្យយើងលេងនៅមុខមនុស្សដើម្បីឲ្យគេសរសើរ ឲ្យយើងរស់នៅដោយដឹងថាយើងទន្ទឹងរង់ចាំការសរសើរពីព្រះជាម្ចាស់។ អ្វីដែលសំខាន់បំផុត យើងធ្វើយ៉ាងណាដើម្បីឲ្យព្រះជាម្ចាស់សប្បាយចិត្តនឹងយើង ដើម្បីឲ្យជីវិតរបស់យើងគាប់ព្រះហឫទ័យព្រះជាម្ចាស់។ ដើម្បីឲ្យព្រះជាម្ចាស់សរសើរ យើងត្រូវការតស៊ូច្រើន ធម្មទេសនារបស់ព្រះយេស៊ូបានណែនាំជីវិតរបស់យើង ពីផ្លូវនៃសុភមង្គលរហូតដល់ពេល

នេះ **"អ្នកណាដែលយំមានសុភមង្គលហើយ អ្នកណាដែលស្រេកឃ្លានយុត្តិធម៌មានសុភមង្គលហើយ..."** យើងអញ្ជើញមិត្តភក្តិរបស់យើងហូបបាយស្រួលណាស់ ប៉ុន្តែអញ្ជើញសត្រូវរួមតុជាមួយគ្នាមិនស្រួលសោះ។ ធម្មទេសនាដែលព្រះយេស៊ូដែលយើងបានស្តាប់ វាផ្ទុយនឹងធម្មជាតិរបស់មនុស្ស **"ស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់មនុស្សលោក"**។ ការលំបាករបស់យើងគឺ ធ្វើដូចម្តេចដើម្បីអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូដែលអប់រំដឹកនាំជីវិតរបស់យើង ដើម្បីភ្ជាប់ភាពដ៏វិសុទ្ធជាមួយព្រះជាម្ចាស់ ជួនកាលណែនាំឲ្យលោកីយ៍មិនសរសើរទេ។ ទោះបីយើងរស់នៅមិនចុះសម្រុងនឹងគ្នា ឲ្យយើងទៅជាបងប្អូនដែលចេះយល់ចិត្តគ្នាដើម្បីធ្វើដំណើរជាមួយគ្នា ដោយយកព្រះបន្ទូលរបស់ព្រះយេស៊ូមកបំភ្លឺជីវិតរបស់យើង។ ធ្វើយ៉ាងណា ដើម្បីកែប្រែចិត្តគំនិតពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារយើងទាំងអស់គ្នាជាមនុស្សមានបាប ហើយយើងក៏ពោរពេញដោយធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដែលបានលើកលែងទោសឲ្យយើង។ ដូច្នេះ យើងទទួលស្គាល់ថាអ្នកដែលធ្វើខុសព្រះជាម្ចាស់លើកលែងទោសឲ្យ ដើម្បីកុំឲ្យគេធ្លាក់ថែមទៀតៗ ផ្ទុយទៅវិញពេលព្រះជាម្ចាស់លើកលែងទោសឲ្យគេហើយ ជួយគេដើម្បីឲ្យគេទៅមុខនៅក្នុងជីវិតជាគ្រីស្តបរិស័ទ នៅក្នុងជីវិតជាគ្រីស្តទូតរបស់ព្រះគ្រីស្ត ដើម្បីឲ្យយើងរួមគ្នាកសាងព្រះសហគមន៍របស់ព្រះយេស៊ូ។ អោយយើងរស់នៅដោយដឹងថាមានតែព្រះជាម្ចាស់ ដែលប្រគល់រង្វាន់ឲ្យយើងគឺជីវិតអស់កល្បជានិច្ច។ យើងជាបូជាចារ្យ និងនិស្សិតទេវវិទ្យាល័យ មានតួនាទីមួយ ណែនាំឲ្យបងប្អូនអាចដើរលើផ្លូវនៃការសង្គ្រោះ នៃជីវិតអស់កល្បជានិច្ច។ យើងខិតខំធ្វើអំពើល្អ គឺដើម្បីផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងដើម្បីរស់នៅក្នុងអំណរសប្បាយនិងសេចក្តីស្រឡាញ់ ដែលព្រះជាម្ចាស់ប្រទានឲ្យ។

តើព្រះជាម្ចាស់របស់ព្រះយេស៊ូគង់នៅឯណា? ឲ្យយើងធ្វើដំណើរដោយទទួលចរិតនិងឥរិយាបថដើម្បីមានចិត្តសោះចំពោះព្រះជាម្ចាស់ ដើម្បីណែនាំឲ្យជីវិតរបស់យើងគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដោយដឹងថាអ្វីដែលមនុស្សយើងកោតសរសើរ អ្វីដែលគេរិះគន់ឲ្យយើងស្តាប់ តែកុំឲ្យយើងវង្វេងស្មារតីដោយសារមានការកែប្រែចិត្តគំនិតរបស់យើងដែលសំខាន់។ យើងអរព្រះគុណព្រះជាម្ចាស់ ដើម្បីឲ្យឆ្នាំសិក្សាកន្លងទៅនេះ អរព្រះគុណព្រះជាម្ចាស់សម្រាប់អ្វីដែលយើងបានទទួលទាំងល្អទាំងមិនល្អ យើងអធិដ្ឋានដើម្បីឲ្យរយៈពេលសម្រាកបីខែខាងមុននេះ ឲ្យយើងរស់នៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលដឹកនាំជីវិតរបស់យើង និងដែលណែនាំឲ្យយើងរស់នៅក្នុងសុភមង្គលដ៏ពិតប្រាកដ។ អាម៉ែន៕